៣៥/៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបាត់ដំបង

សាលក្រមព្រហ្មទណ្ឌលេខ:៧២៦(ជ)
ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២
សំណុំរឿងព្រហ្មទណ្ឌលេខ:១៤៣១
ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១

## នាមប្រជាពលរដ្ឋខ្មែរ
## តុលាការខេត្តបាត់ដំបង

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្តបាត់ដំបង

**នៅថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦**

**ត្រូវនឹងថ្ងៃទី០៥ ខែកក្កដា ឆ្នាំ ២០២២**

***សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ***

លោក [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ជាចៅក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រុមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញារង

ក្រឡាបញ្ជីសវនាការ

លោក [redacted] ជាក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ:១៤៣១ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិអូ [redacted] ខេត្តកំពង់ចាម កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (រ) មេម៉ាយ មានកូន៣នាក់ ជានីតិជន កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុន គ្មាន។(ក្នុងឃុំ)

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១៨១៩ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០(កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងភាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

២.ឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៥ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ កើតនៅភូមិ [redacted] ខេត្តតាកែវ កាន់សាសនាព្រះពុទ្ធ មានទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ពោះម៉ាយ មានកូន៣នាក់ ជានីតិជន កម្រិតវប្បធម៌មិនចេះអក្សរ ទោសពីមុន មាន៍ [illegible](ក្នុងឃុំ)



Scanned with CamScanner

-ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ:១៩១៨ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២១។

ជនជាប់ចោទត្រូវបានជាប់ចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម តាមបញ្ញត្តិមាត្រា៤០(កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៨) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

-មានលោកស្រី [redacted] នីតីយ៉ាណា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

**អង្គហេតុនៃរឿងក្តី:**

កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១៧និង០០នាទី នៅចំណុចភូមិ [redacted] រៀង ខេត្តបាត់ដំបង កម្លាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបករណីគ្រឿងញៀនមួយ ដែលបង្កដោយឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ បានទិញគ្រឿងញៀនចំនួន១ជ្រុង ក្នុងតម្លៃ៦០ម៉ឺនរៀល ពីឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ដើម្បីយកមកលែកលក់បន្ត។ ដោយគ្រឿងញៀនទាំងនេះឈ្មោះ [redacted] ផៃ ហៅ ថៃ បានទិញបន្តពីឈ្មោះ ម៉ៅ ភេទប្រុស ម្តងៗចំនួន៥ខាំ ក្នុង១ខាំតម្លៃ៤០០$ ដើម្បីយកមកលែកលក់បន្តទៀត។ លុះនៅថ្ងៃកើតហេតុពេលកំពុងធ្វើសកម្មភាពក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានថ្នាំញៀនសរុប៥៨៤,៨៧ក្រាម(ទាំងសំបក) នេះតែម្តង។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ:៨៥៧ ដស.បស ចុះថ្ងៃទី០៥-១១-២០២១។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ:៨៩ ចុះថ្ងៃទី០១-០២-២០២២។

-បានឃើញ ដីកាដំណោះស្រាយលេខ:១៨៨ ចុះថ្ងៃទី០១-០៣-២០២២។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខ:២២៥១ ចុះថ្ងៃទី២៨-០៤-២០២២។

**នាពេលសវនាការ:**

-ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា។

-ក្រោយពីបានស្តាប់ ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផៃ។

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ។

-ក្រោយពីបានស្តាប់ សម្តីចុងក្រោយរបស់ជនជាប់ចោទ។

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់សាលាដំបូងខេត្តបាត់ដំបង**

**យល់ឃើញថា:**

១.កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១៧និង០០នាទី នៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កម្លាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបករណីគ្រឿងញៀនមួយ ដែលបង្កដោយឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ បានទិញគ្រឿងញៀនចំនួន១ជ្រុង ក្នុងតម្លៃ៦០ម៉ឺនរៀល ពីឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ដើម្បីយកមកលែកលក់បន្ត។ ដោយគ្រឿងញៀនទាំងនេះឈ្មោះ [redacted] ផៃ ហៅ ថៃ បានទិញបន្តពីឈ្មោះ ម៉ៅ ភេទប្រុស ម្តងៗចំនួន៥ខាំ ក្នុង១ខាំតម្លៃ៤០០$ ដើម្បីយកមកលែកលក់បន្តទៀត។ លុះនៅថ្ងៃកើត

ហេតុពេលកំពុងធ្វើសកម្មភាពក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួន និងដកហូតបានថ្នាំញៀនសរុប៥៨៥,៨៧ក្រាម(ទាំងសំបក) នេះតែម្តង។

២.តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា បានឆ្លើយនាពេលសវនាការថាៈខ្លួនធ្លាប់បានស្គាល់ឈ្មោះ [redacted] ផៃ យូរមកហើយប៉ុន្តែមិនធ្លាប់មានទំនាក់ទំនងគ្នាទេ។ ទើបតែពេលថ្មីៗនេះ ខ្លួនបានសុំលេខទូរស័ព្ទគាត់ និងបានសាកល្បងទាក់ទងទិញគ្រឿងញៀនពីគាត់ ព្រោះខ្លួនធ្លាប់បានដឹងថាគាត់ជាអ្នករកស៊ីលក់ដូរគ្រឿងញៀនពីមុនមក។ បន្ទាប់ពីទាក់ទងឈ្មោះ [redacted] ផៃ មកខ្លួនបានទាក់ទងទិញគ្រឿងញៀនពីគាត់ចំនួនសរុបមកបាន៨លើក ប៉ុន្តែលើកទី១ និងលើកទី២ មិនបានសម្រេចទេ។ រហូតដល់ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ទើបទាក់ទងទិញគ្រឿងញៀនពីគាត់បានចំនួន១ជ្រុង ដែលមានតម្លៃ៦០០.០០០រៀល ប៉ុន្តែគាត់ថាយកពីខ្លួនត្រឹមតែ៤០០.០០០រៀលទេ។ គ្រឿងញៀននេះគាត់ឱ្យមកខ្លួនទៅលក់សិន ពេលបានប្រាក់ទើប គាត់យកពីខ្លួនវិញ។ បន្ទាប់ពីទទួលបានគ្រឿងញៀនហើយ ខ្លួនយកទៅប្រើប្រាស់ជុំគ្នាជាមួយមិត្តភក្តិ និងលក់បន្ត។ នៅថ្ងៃដដែលនោះ មានអ្នកទាក់ទងមកទិញគ្រឿងញៀនពីខ្លួន ហើយពេលដែលខ្លួនយកគ្រឿងញៀនទៅឱ្យគេ ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ពេលឃាត់ខ្លួនសមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួន៥កញ្ចប់ និងទូរស័ព្ទចំនួន១គ្រឿង។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនយូរមកហើយ ប៉ុន្តែខ្លួនទើបតែហ៊ានលក់ដូរគ្រឿងញៀនលើកទី១ ប៉ុណ្ណោះ ដោយសារខ្លួនគ្មានលទ្ធផលជួលកន្លែងស្នាក់នៅ។

៣.តាមការស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ផៃ នាពេលសវនាការថាៈកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានទាក់ទងទិញគ្រឿងញៀនពីឈ្មោះ ម៉ៅ ភេទប្រុស អាយុប្រហែល៦០ឆ្នាំ រស់នៅខេត្តបន្ទាយមានជ័យ។ បន្ទាប់មកឈ្មោះ ម៉ៅ បានឱ្យមនុស្សស្រី២នាក់ ណាត់ជួបគ្នាជាមួយខ្លួន ដើម្បីទទួលយកគ្រឿងញៀនប្រភេទម៉ាទឹកកកចំនួន៥ខាំ។ គ្រឿងញៀននេះ តម្លៃ៤០០$ក្នុង០១ខាំ។ ខ្លួនមិនទាន់បានឱ្យប្រាក់ទៅឈ្មោះ ម៉ៅ នោះទេលុះត្រាតែខ្លួនលក់អស់សិន ទើបឱ្យលុយទៅឈ្មោះ ម៉ៅ ហើយឈ្មោះ ម៉ៅ ជាអ្នកបែងចែកឱ្យបាទវិញ។ ក្រៅពីឈ្មោះ ម៉ៅ ខ្លួនមិនបានទាក់ទងទៅនរណាទេ។ បន្ទាប់ពីទទួលបានគ្រឿងញៀនហើយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១ ខ្លួនបានយកមកបែងចែករំលែកលក់ឱ្យទៅឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ចំនួន០១ជ្រុង តម្លៃ៤០០.០០០រៀល ប៉ុន្តែមិនទាន់ទទួលបានប្រាក់ទេ។ បន្ទាប់មកឈ្មោះ [redacted] ស៊ីណា បានទាក់ទងមកទិញចំនួនកន្លះជ្រុងទៀត តម្លៃ២០០.០០០រៀល ហើយពេលដែលយកគ្រឿងញៀនទៅប្រគល់ឱ្យឈ្មោះ [redacted] ស៊ីណា ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ សមត្ថកិច្ចបានដកហូតគ្រឿងញៀនចំនួនកន្លះជ្រុងនៅក្នុងហោប៉ៅ និងទូរស័ព្ទដៃចំនួន០១គ្រឿង រួចបានបន្តទៅឆែកឆេរនៅផ្ទះសំណាក់ ឃើញមានគ្រឿងញៀន០១កញ្ចប់ធំទៀត រួមជាមួយជញ្ជីងសម្រាប់ថ្លឹងគ្រឿងញៀន។ ខ្លួនត្រូវបានតុលាការខេត្តបាត់ដំបងផ្តន្ទាទោសដាក់ពន្ធនាគារចំនួន៨ឆ្នាំ ម្តងហើយពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀននៅឆ្នាំ២០១៧ទើបតែចេញមកវិញនៅឆ្នាំ២០២០។

៤.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា និងឈ្មោះ [redacted] ផៃ ហៅ ថៃ ដែលបាននាំធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលអំពើទាំងអស់នេះ ជាអំពើបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ជាពិសេសប៉ះពាល់ដល់សុខភាពរាងកាយរបស់អ្នកដទៃ ដែលច្បាប់ការពារ និងកំណត់ថាជាអំពើល្មើសព្រហ្មទណ្ឌ និងមាន[illegible]ផ្តន្ទាទោស។

៥.បានឃើញលទ្ធផលកោសលវិច័យលេខៈ[illegible] ម.ព.អ.ផ.ប.គ.ញ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ សំណាកជាប្រភេទក្រាមម្សៅថ្លា ពណ៌ស ទម្ងន់[illegible]ក្រាម បញ្ជាក់ថាលទ្ធផលវិជ្ជមាន ,វត្ត

មានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន បរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៨.៥០% ជារបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា។

៦.បានឃើញលទ្ធផលកោសល្យវិច័យលេខ:៣៨៥៨០/២២ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ ២០២២ សំណាកទី១ ជាប្រភេទក្រោមម្សៅថ្លា,ពណ៌ស ទម្ងន់៧.៨៩៣៩ក្រាម បញ្ជាក់ថាលទ្ធផលវិជ្ជមាន,វត្ថុ មានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន បរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ ៧៨.៥០%។ សំណាកទី២ ជាប្រភេទគ្រាប់ចំនួន១គ្រាប់ ពណ៌ក្រហម វិជ្ឈមាត្រ៦មិល្លីម៉ែត្រ កម្រាស់៣មិល្លីម៉ែត្រ ទម្ងន់សរុប០.០៩៧០ក្រាម រូបរាង មូលប៉ោងសងខាង សញ្ញាសម្គាល់Logo WY បញ្ជាក់ថាលទ្ធផលវិជ្ជមាន,វត្ថុមានសារធាតុញៀនឈ្មោះមេតំហ្វេតាមីន បរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់គឺ១៥.៣៧% ជារបស់ជនជាប់ចោទឈ្មោះ [redacted] ផៃ។

៧.មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

៨.មានភស្តុតាងនិងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ផៃ ហៅថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៥) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

៩.ជនជាប់ចោទមានកាយសម្បទារគ្រប់គ្រាន់ ពុំមានសញ្ញាណណាមួយបញ្ជាក់ថាមានបញ្ហាវិបល្លាស ផ្នែកស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវទទួលចំពោះមុខច្បាប់ជាធរមានចំពោះព្យសនកម្ម ដែលកើតចេញពីអំពើល្មើសរបស់ខ្លួនដែលបានប្រព្រឹត្ត។

១០.វត្ថុតាងរួមមាន៖

-គ្រឿងញៀនជាប្រភេទម្សៅក្រាម ពណ៌សថ្លា ចំនួន១០,៩២ក្រាម ដែលនៅសល់ពីការដកសំណាក ជារបស់ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា។

-គ្រឿងញៀនជាប្រភេទម្សៅក្រាម ពណ៌សថ្លា ចំនួន៥២៥,១០ក្រាម ដែលនៅសល់ពីការដកសំណាក ជារបស់ជនជាប់ចោទឈ្មោះ [redacted] ផៃ។

-ទូរស័ព្ទដៃចាស់ចំនួន២គ្រឿង,ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនលក់ចំនួន២គ្រឿង និងថង់សម្រាប់រំលែកថ្នាំញៀនលក់មួយចំនួន។

១១-តំណាងអយ្យការនាពេលសវនាការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted] ស៊ីណា សារភាពថាបានទិញគ្រឿងញៀនតម្លៃ៦០០.០០០រៀលពីជនជាប់ចោទឈ្មោះ [redacted] ផៃ។ ជនជាប់ចោទទាំងពីរនាក់បានទទួលស្គាល់បទចោទ។ ជនជាប់ចោទឈ្មោះ ស្រ៊ុន ផៃ ស្ថិតក្នុងស្ថានភាពមិនរាងចាល។ សុំតុលាការផ្តន្ទាទោសជនជាប់ចោទទៅតាមច្បាប់។

១២.មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទធ្វើសេចក្តីសន្និដ្ឋានៈ ជនជាប់ចោទបានសារភាពនូវទោសកំហុសរបស់ខ្លួនរៀងៗខ្លួន ដោយសោកស្តាយនូវអំពើរបស់ខ្លួន។ សុំតុលាការសម្រាលទោសឱ្យកូនក្តីខ្លួនដោយអនុគ្រោះ។

១៣.សម្តីចុងក្រោយរបស់ជនជាប់ចោទៈស្នើសុំតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួនផង គប្បីតុលាការលើកមកពិចារណាក្នុងការសម្រេចសេចក្តី។

## ហេតុដូច្នេះសាលាដំបូងខេត្តបាត់ដំបង
## វិនិច្ឆ័យសេចក្តី

I.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ស៊ីណា ភេទស្រី អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល០៦(ប្រាំមួយ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន១០០០០០០០៛(ដប់លានរៀល) ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា៤០(កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុកកំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

II.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ផៃ ហៅ ថៃ ភេទប្រុស អាយុ៥៩ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល២០(ម្ភៃ)ឆ្នាំ និងពិន័យជាប្រាក់កំណត់ចំនួន៤០០០០០០០៛(សែសិបលានរៀល) ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងមិនរាងចាលក្នុងបទឧក្រិដ្ឋបន្ទាប់ពីការផ្តន្ទាទោសបទមជ្ឈិម តាមបញ្ញត្តិមាត្រា៤០ (កថាខណ្ឌ៣ និងកថាខណ្ឌ៧ ចំណុច៨) នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៨៧ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅចំណុចភូមិស្វាយធំ ឃុំបឹងរាំង ស្រុក កំរៀង ខេត្តបាត់ដំបង កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២១។

III.រឹបអូសវត្ថុតាងរួមមានៈ

-គ្រឿងញៀនជាប្រភេទម្សៅក្រាម ពណ៌សថ្លា ចំនួន១០,៩២ក្រាម និង គ្រឿងញៀនជាប្រភេទម្សៅក្រាម ពណ៌សថ្លា ចំនួន៥២៥,១០ក្រាម ដែលនៅសល់ពីការដកសំណាក ។

-ទូរស័ព្ទដៃចាស់ចំនួន០២គ្រឿង,ជញ្ជីងសម្រាប់ថ្លឹងថ្នាំញៀនលក់ចំនួន២គ្រឿង និងថង់សម្រាប់វែលកថ្នាំញៀនលក់មួយចំនួន។

សាលក្រមនេះប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តបាត់ដំបងនៅថ្ងៃអង្គារ ០៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ពស.២៥៦៦ ត្រូវនឹងថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២។

សម្រេចសេចក្តីចំពោះមុខជនជាប់ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមប្រឹក្សា

[redacted]

ចៅក្រមប្រឹក្សា

[redacted]

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]